TACOMA
PUBLIC SCHOOLS

**Carla Santorno**
Superintendent

p: 253-571-1010
f: 253-571-1440
csantor@tacoma.k12.wa.us

**tacomaschools.org**

**សូមគោរពជូនក្រុមគ្រួសារសិស្សជាទីរាប់អាន**

សាលា Tacoma Public Schools បានប្តេជ្ញាចិត្តក្នុងការធានាថា សិស្សរបស់យើងមានសុវត្ថិភាព បានទទួលការស្វាគមន៍ និងការគោរពនៅសាលារៀន។

ដូចដែលខ្ញុំបានចែករំលែកជាមួយអ្នកនៅខែមករា ករណីសម្លុត យាយី បំភិតបំភ័យ ឬរើសអើងមិនកើតឡើងទេនៅក្នុងសាលា Tacoma ។ យើងចង់ឱ្យការលះលង់របស់សាលា Tacoma ដើម្បីសមធម៌ ការយល់ដឹង និងការគោរពនៅតែបន្តនៅទីនេះ។ នោះហើយជាមូលហេតុដែលខ្ញុំចង់អះអាងចំពោះអ្នកថា សាលា Tacoma Public Schools នឹងមិនរេរានៅក្នុងតួនាទីរបស់ខ្លួនជាអ្នកមើលទាំកូនសិស្សក្នុងសាលា Tacoma ឡើយ។

**សាលារៀនរបស់យើងនឹងក្លាយជាតំបន់មានសុវត្ថិភាពសម្រាប់សិស្សអន្តោប្រវេសន៍**រៀនសូត្រ និងចម្រុងចម្រើន។ ភាពសម្បូរបែបនៃសិស្សានុសិស្សរបស់យើង សហគមន៍របស់យើងនិងបុគ្គលិករបស់យើងជាកម្លាំងមួយដែលផ្តល់ផលប្រយោជន៍ដល់យើងទាំងអស់គ្នា និងគួរតែត្រូវបានអបអរសាទរ។ វប្បធម៌សម្បូរបែបរបស់យើង និងភាសាច្រើនជាង 70 ភាសាផ្សេងៗគ្នាដែលនិយាយនៅក្នុងសាលារបស់យើងបានផ្តល់ឲ្យកុមារទាំងអស់នូវឱកាសរៀនពីកុមារដទៃទៀតដែលមានប្រវត្តិខុសៗគ្នា និងទទួលស្គាល់មនុស្សជាតិរួមរបស់យើង។

បេសកកម្មរបស់យើងគឺដើម្បីបម្រើដល់កុមារគ្រប់រូបដែលបានមកដល់ក្លោងទ្វារសាលារបស់យើងជារៀងរាល់ថ្ងៃ។
យើងនឹងបន្តផ្តល់ជូនសិស្សទាំងអស់នូវសិទ្ធិស្របច្បាប់ក្នុងការទទួលបានការអប់រំដល់ថ្នាក់ទី 12  ដោយឥតគិតថ្លៃដោយមិនគិតពីសាសនា កន្លែងកំណើត ភាសា សញ្ជាតិ ស្ថានភាពអន្តោប្រវេសន៍ ស្ថានភាពឪពុកម្តាយរបស់ពួកគេ ឬលក្ខណៈណាមួយផ្សេងទៀតទទួលបានការការពារស្របច្បាប់ ។ សាលា Tacoma Public Schools មិនស្នើសុំ ឬតាមដានសញ្ជាតិ ឬស្ថានភាពអន្តោប្រវេសន៍របស់សិស្ស។ លើសពីនេះទៀត នៅក្រោមច្បាប់សហព័ន្ធស្តីពីសិទ្ធិអប់រំ និងសិទ្ធិឯកជន (FERPA) សញ្ជាតិ ឬស្ថានភាពអន្តោប្រវេសន៍របស់សិស្សគឺជាព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គល ដែលមិនអាចបញ្ចេញឲ្យដឹងជាសាធារណៈ។

សាលារៀនទាំងអស់ត្រូវបានណែនាំឲ្យផ្តល់នូវទីកន្លែងដែលមានសុវត្ថិភាព និងឯកជនដែលសិស្សអាចរកជំនួយ ព័ត៌មាន និងការគាំទ្រពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់អន្តោប្រវេសន៍ណាមួយដែលរារាំងដល់ការទទួលនូវបទពិសោធន៍នៃការសិក្សារបស់ពួកគេ។ *ដើម្បីគាំទ្រដល់ការងារនេះ គណៈកម្មការសាលារបស់យើងនឹងធ្វើការវាយតម្លៃសេចក្តីសម្រេចមួយក្នុងការគាំទ្រសិស្សទាំងអស់ជារៀងរាល់ថ្ងៃនៅក្នុងបរិយាកាសមួយប្រកបដោយសមធម៌  និងបរិយាប័ន្ន។*

កិច្ចការខ្លះនៅក្នុងពិភពលោករបស់យើងបានផ្លាស់ប្តូរ ហើយប៉ុន្តែភារកិច្ចជាមូលដ្ឋានរបស់យើងនៅក្នុងសាលា Tacoma Public Schools គឺនៅដដែល។
គោលដៅរបស់យើងនៅដដែល គឺចង់ឲ្យសិស្សទាំងអស់នៅក្នុង Tacoma Public Schools នឹងបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ និងត្រៀមចាប់យកអាជីព។
យើងនៅតែប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍកុមារទាំងមូល។ យើងកំពុងរៀបចំឱ្យសិស្សក្លាយទៅជាពលរដ្ឋល្អនៅក្នុងសង្គមសាកល។

ថ្ងៃនេះ និងរាល់ថ្ងៃ **សិស្សទាំងអស់ត្រូវបានស្វាគមន៍**នៅសាលា Tacoma Public Schools។



Carla J. Santorno